

The Committee on the Rights of the Child (CRC Committee) is preparing a General Comment on Access to Justice and Remedies (GC27). Consultations with different stakeholders, including children, take place across the world.



A group of children and youth, 13 to 19 years of age, with different identities and backgrounds from around Cambodia gathered to support this work by responding to the Committee's questions. In total, 12 girls and 15 boys took part in the consultations in November 2024. Ten of them participated in the validation workshop in December 2024.

Child Rights Coalition Cambodia (CRC-Cambodia) with partners organized the consultations with children in Cambodia, based on this methodology and using this child friendly information. Key results from the consultations are collected in this report.



PLEASE NOTE - statements in speech bubbles are not direct quotes from children but paraphrases developed based on children's opinions and views collected in consultations.



គណៈកម្មាធិការសិទ្ធិកុមារ (CRC Committee) កំពុងរៀបចំមតិទូទៅស្ដីពីសិទ្ធិទទួលបានយុត្តិធម៌ និងសំណង (GC27)។ ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធផ្សេងៗ រួមទាំងកុមារ ធ្វើឡើងនៅទូទាំងពិភពលោក។



កុមារ និងយុវជនមួយក្រុមមានអាយុចន្លោះពី១៣ឆ្នាំ ដល់១៩ឆ្នាំ ដែលមានអត្តសញ្ញាណ និងសាវតាខុសៗគ្នាមកពីជុំវិញប្រទេសកម្ពុជាបានប្រមូលផ្ដុំគ្នាដើម្បីគាំទ្រការងារនេះដោយបានឆ្លើយតបទៅនឹងសំណួររបស់គណៈកម្មាធិការ។ ក្មេងស្រី ១២ នាក់ និងក្មេងប្រុស ១៥ នាក់បានចូលរួមក្នុងការពិគ្រោះយោបល់នេះក្នុងខែវិច្ឆិកា ឆ្នាំ២០២៤។ ១០នាក់ក្នុងចំណោមនោះបានចូលររួមកិច្ចពិភាក្សារការធ្វើសុពលភាពព័តមានក្នុង ខែធ្នូ ឆ្នាំ២០២៤។

អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា (CRC-Cambodia) ជាមួយដៃគូបានរៀបចំការពិគ្រោះយោបល់ជាមួយកុមារនៅកម្ពុជា ដោយផ្អែកលើវិធីសាស្ត្រ និងការប្រើប្រាស់ព័ត៌មានដែលមានលក្ខណៈបែបកុមារមេត្រី។ លទ្ធផលសំខាន់ៗពីកិច្ចពិភាក្សាត្រូវបានប្រមូលដាក់ក្នុងរបាយការណ៍នេះ។



ព័តមានដែលបានលើកឡើងនៅក្នុងប្រអប់នីមួយៗ មិនមែនជាការដកស្រង់សំដីដោយផ្ទាល់ពីក្រុមកុមារទេ ប៉ុន្តែពាក្យប្រៀបធៀបត្រូវបានបង្កើតឡើងដោយផ្អែកលើគំនិត និងទស្សនៈរបស់កុមារដែលប្រមូលបាននៅក្នុងកិច្ចភាក្សា



## Access to Justice and Effective Remedies

- When childrenś rights are violated, children should have a possibility to go to bodies/institutions delivering justice and ask for support and to fix this situation - this is called access to justice.
- Effective remedy is when these bodies make decisions that make a positive change for children on time. This decision includes: identifying rights that were violated, who did it, and what should happen next to fix the situation, repair the harm, and make sure it doesn't happen again.

## Reporting and Justice Mechanisms - Key Steps

1. Child or a group of children makes a report, complaint or contacts such a body to tell them about what happened.
2. The body
   - collect more information
   - think over all the information collected
   - listens to children
3. The body makes a decision that is good for the child or children and makes sure that the government and others take responsibility.

## Justice and effective remedies from the perspective of children and youth in Cambodia

When adults (those in power/decision-makers)

- make laws and decisions that are fair/just/right for all, including children, respect these laws, and follow through decisions and promises they made
- take responsibility and correct mistakes they made
- treat everyone the same way, and are being fair to everyone, including children no matter where they come from
- do not apply special rights for some and do not misuse power, make threats or request informal payments (corruption and bribery)

When children

- are safe, respected, and get support and care they need during the process. When decisions made (remedies/solutions) in this process are suitable/good for children and they are carried out (made happen).

## Services available to children in Cambodia in their communities. Children can go to these places to get advice or to report problems related to their rights:







- There is no Ombudsperson in Cambodia (yet).
- Cambodia has not (yet) agreed with the CRC Optional Protocol 3 that makes it possible to communicate violations of childrenś rights to the Committee (after all options at the national level did not give results).



## សិទ្ធិទទួលបានយុត្តិធម៌ និងសំណង

- នៅពេលដែលសិទ្ធិកុមារត្រូវបានរំលោភបំពាន កុមារគួរតែមានលទ្ធភាពទៅកាន់ស្ថាប័នផ្តល់យុត្តិធម៌ និងសុំការគាំទ្រ និងដើម្បីដោះស្រាយស្ថានភាពនេះ ហៅថា សិទ្ធិទទួលបានយុត្តិធម៌។
- សំណងដែលមានប្រសិទ្ធភាពគឺនៅពេលដែលស្ថាប័នទាំងនេះធ្វើការសម្រេចចិត្តដែលធ្វើឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានសម្រាប់កុមារទាន់ពេលវេលា។ ការសម្រេចចិត្តនេះរួមបញ្ចូល៖ ការកំណត់អត្តសញ្ញាណនៃសិទ្ធិដែលត្រូវបានរំលោភបំពាន អ្នកណាជាអ្នកធ្វើ និងអ្វីដែលគួរកើតឡើងបន្ទាប់ដើម្បីកែប្រែស្ថានភាព ប៉ះប៉ូវការខូចខាត និងត្រូវប្រាកដថាវានឹងមិនកើតឡើងម្តងទៀត។



## ជំហានសំខាន់ៗនៅក្នុងយន្តការរាយការណ៍ និងយុត្តិធម៌




## យុត្តិធម៌ និងសំណងប្រកបដោយប្រសិទ្ធភាព តាមទស្សនៈរបស់កុមារ និងយុវជននៅកម្ពុជា

នៅពេលមនុស្សពេញវ័យ (អ្នកដែលមានអំណាច/អ្នកធ្វើការសម្រេចចិត្ត)

- បង្កើតច្បាប់ និងការសម្រេចចិត្តដែលត្រឹមត្រូវ/យុត្តិធម៌/ត្រឹមត្រូវសម្រាប់ទាំងអស់គ្នា រួមទាំងកុមារ គោរពច្បាប់ទាំងនេះ ហើយអនុវត្តតាមការសម្រេចចិត្ត និងការសន្យាដែលពួកគេបានធ្វើ។
- ទទួលខុសត្រូវ និងកែកំហុសដែលខ្លួនបានធ្វើកម្លងមក។
- អនុវត្តន៍ដូចគ្នាចំពោះមនុស្សគ្រប់គ្នា ហើយមានភាពយុត្តិធម៌ចំពោះមនុស្សគ្រប់គ្នា រួមទាំងកុមារមិនថាពួកគេមកពីណាក៏ដោយ។
- មិនមានសិទ្ធិពិសេសសម្រាប់មនុស្សដាច់ដោយឡែក និងគ្មានការប្រើប្រាស់អំណាចខុស គ្មានការគំរាមកំហែង គ្មានការបង់ប្រាក់ក្រៅផ្លូវការ/បន្ថែម (អំពើពុករលួយ និងសំណូក)

នៅពេលកុមារ

- មានសុវត្ថិភាព ការគោរព និងទទួលបានការគាំទ្រ និងការថែទាំដែលពួកគេត្រូវការក្នុងអំឡុងពេលនៃដំណើរការ។ នៅពេលដែលការសម្រេចចិត្តដែលបានធ្វើឡើង (សំណង/ដំណោះស្រាយ) នៅក្នុងដំណើរការនេះគឺសមរម្យ/ល្អសម្រាប់កុមារ ហើយពួកគេត្រូវបានអនុវត្ត (ធ្វើឱ្យវាកើតឡើង)។

**ប្រភេទសេវាកម្មដែលមានសម្រាប់កុមារនៅប្រទេសកម្ពុជាក្នុងសហគមន៍របស់ពួកគេ។ កុមារអាចទៅកន្លែងទាំងនេះដើម្បីទទួលបានដំបូន្មាន ឬរាយការណ៍ពីបញ្ហាទាក់ទងនឹងសិទ្ធិរបស់ពួកគេ៖**







- នៅកម្ពុជាមិនទាន់មានអ្នកតំណាងឯករាជ្យ (ក្នុងវិស័យនេះ)។
- កម្ពុជាមិនទាន់បានផ្តល់សច្ចាប័នលើពិធីសារបន្ថែម Optional Protocol 3 ដែលអាចដាក់បណ្តឹងទៅកាន់គណៈកម្មាធិការបាននៅពេលសិទ្ធិកុមារត្រូវបានរំលោភបំពាន (បន្ទាប់ពីពិធីសារទាំងអស់នៅថ្នាក់ជាតិមិនទាន់ផ្តល់លទ្ធផល)។

What difficulties children face in accessing - finding and speaking to a body delivering justice when their rights have been violated?

Are there groups of children for whom it is even more difficult?
If yes, who and why?



Committee on the Rights of the Child

តើកុមារមានបញ្ហាប្រឈម និងការ
លំបាកអ្វីខ្លះក្នុងការចូល ឬស្វែងរក
និងនិយាយទៅកាន់ស្ថាប័នផ្តល់យុត្តិ
ធម៌ នៅពេលដែលសិទ្ធិរបស់ពួកគេ
ត្រូវបានរំលោភបំពាន?

តើមានក្រុមកុមារដែលមានការ
ពិបាកជាងនេះទេ? បើមាន តើ
ក្រុមណា និងហេតុអ្វី?



គណៈកម្មាធិការសិទ្ធិកុមារ




## children are not informed

- Children do not know where and how to report a problem or to file a complaint.
- Children do not learn about this in schools nor are they getting advice from social workers, doctors etc.
- NGOs give legal advice to children when they need it. Information about what to do when rights are violated is not part of the usual information/learning about child rights.
- There is a focal point for child protection in the villages, but children do not know about this.
- When information is given, difficult words are used.

Children find out about a hotline on their own on social media.

This is even more difficult for indigenous children, children with disabilities and young children. They do not get information in the language they can understand well.

Police and others use words that are not easy to understand. Sometimes they use offensive words and yell.

## reporting and justice process - not acceptable

- In the villages, all the police officers are men. This makes girls feel uncomfortable/hesitant talking about what happened. There are not many female lawyers or prosecutors.
- Many children and their families are scared or don't want to report problems and start legal processes because they don't trust the system.
- Generally, people think/expect that children should be quiet and not speak up or complain to adults.

Many children and families are afraid of bribery.

Many children and families are afraid that they will not be treated well and fair, and suffer more instead of getting help.

SOGIESC-diverse, poor and children without parents are even more discouraged.

Children are shy. Some can not even talk about problems with their parents.



# 1

# Access



## court process is not affordable

- Legal procedures are costly. Many children/families do not have money or do not want to risk it.
- Children do not get free legal support.
- Unofficial and additional costs are required for some essential services.

Litigation is expensive. Families spend a lot of money, but they don't get any good compensation or help.

Poor children are neglected in hospitals and schools because they can not pay unofficial and/or additional costs.

## physically not accessible

- Rural and especially remote areas have less services, options and support for children and even less for children with disabilities. Many indigenous children live in remote areas.
- Generally available opportunities might be too far or too expensive.
- There are no ramps and equipment for children with physical disabilities and or children with audio-visual impairments.



Children in rural and remote areas do not have access to internet and this means even less options to find information and advice when they need it.

Everything is even more expensive for children who are far away from centers because they need to pay for travel and accommodation to attend litigations (court cases).

Conclusion: children have many difficulties to access justice, some groups of children are even more discouraged (more ashamed and less confident to raise concerns)

# ការចូលប្រើប្រាស់

១



## កុមារមិនត្រូវបានជូនដំណឹង

- កុមារមិនបានដឹងថាកន្លែងណា និងរបៀបរាយការណ៍ពីបញ្ហា ឬដាក់ពាក្យបណ្តឹងនោះទេ។
- កុមារមិនបានរៀនអំពីរឿងរបៀបទាំងនេះនៅតាមសាលា ឬមិនបានទទួលការប្រឹក្សាពីបុគ្គលិកសង្គមកិច្ច វេជ្ជបណ្ឌិតជាដើម។
- អង្គការក្រៅរដ្ឋាភិបាលផ្តល់ដំបូន្មានផ្នែកច្បាប់ដល់កុមារនៅពេលដែលពួកគេត្រូវការវា។ ព័ត៌មានអំពីអ្វីដែលត្រូវធ្វើនៅពេលដែលសិទ្ធិត្រូវបានរំលោភ មិនមែនជាផ្នែកនៃព័ត៌មានដែលអាចប្រើប្រាស់បាន/ការរៀនអំពីសិទ្ធិកុមារទេ។
- មានជនបង្គោលសម្រាប់ការពារកុមារនៅតាមភូមិ ប៉ុន្តែកុមារមិនបានដឹងអំពីបញ្ហានេះទេ។
- នៅពេលផ្តល់ព័ត៌មាន ពាក្យពិបាកៗតែបន្តប្រើប្រាស់។

កុមារស្វែងយល់អំពីប្រព័ន្ធទូរស័ព្ទបន្ទាន់ដោយខ្លួនឯងនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម។

វាកាន់តែពិបាកសម្រាប់កុមារជនជាតិដើមភាគតិច កុមារពិការ និងកុមារតូចៗ។ ពួកគេមិនទទួលបានព័ត៌មានជាភាសាដែលពួកគេអាចយល់បាននោះទេ។

ប៉ូលីស និងអ្នកផ្សេងទៀតប្រើពាក្យដែលពិបាកយល់។ ពេលខ្លះពួកគេប្រើពាក្យប្រមាថ និងស្រែក។

## របាយការណ៍ និងដំណើរការយុត្តិធម៌ មិនអាចទទួលយកបាន។

- នៅតាមភូមិ មន្ត្រីប៉ូលិសភាគច្រើនសុទ្ធតែជាបុរស។ នេះធ្វើឱ្យក្មេងស្រីមានការលំបាក/ស្ទាក់ស្ទើរក្នុងការនិយាយអំពីអ្វីដែលបានកើតឡើង។ មិនមានមេធាវី ឬព្រះរាជអាជ្ញាជាស្ត្រីច្រើនទេ ហើយបញ្ហាស្រដៀងគ្នានេះអាចកើតឡើងនៅកម្រិតថ្នាក់ជាតិផងដែរ។
- កុមារ និងគ្រួសារជាច្រើនរបស់ពួកគេមានការភ័យខ្លាច ឬមិនចង់រាយការណ៍ពីបញ្ហា និងទទួលយកដំណើរការផ្លូវច្បាប់ ដោយសារតែពួកគេមិនទុកចិត្តប្រព័ន្ធដែលទាក់ទង។
- ជាទូទៅ មនុស្សពេញវ័យគិតថា/រំពឹងថា កុមារគួរតែនៅឱ្យស្ងៀម ហើយមិនត្រូវនិយាយស្តី ឬប្តឹងប្តល់ទៅលើមនុស្សពេញវ័យឡើយ។

កុមារ និងគ្រួសារជាច្រើនខ្លាចការសូកប៉ាន់។

កុមារ និងគ្រួសារជាច្រើនមានការភ័យខ្លាចថា ពួកគេនឹងមិនទទួលបានការយកចិត្តទុកដាក់បានល្អ និងយុត្តិធម៌ ហើយរងទុក្ខច្រើនជាងការទទួលបានជំនួយ។

កុមារដែលមាន SOGIESC-ចម្រុះ កុមារក្រីក្រ និងកុមារដែលគ្មានឪពុកម្តាយគឺកាន់តែមានការធ្លាក់ទឹកចិត្ត។

កុមារមានភាពខ្មាសអៀនច្រើន។ អ្នកខ្លះមិនអាចសូម្បីតែនិយាយអំពីបញ្ហាជាមួយឪពុកម្តាយរបស់ពួកគេ។





## នីតិវិធីតុលាការភាគច្រើនមិនអាចទទួលយកបាន

- នីតិវិធីច្បាប់មានតម្លៃថ្លៃ។ កុមារ/គ្រួសារជាច្រើនមិនមានលុយ ឬមិនចង់ប្រថុយ ឬប្រឈមហានិភ័យទាំងនោះ។
- កុមារមិនទទួលបានជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ។
- ការចំណាយក្រៅផ្លូវការ និងថ្លៃសេវាបន្ថែមត្រូវបានទាមទារសម្រាប់សេវាកម្មសំខាន់ៗមួយចំនួន។

ដំណើរការនៃវិវាទមានតម្លៃថ្លៃ។ គ្រួសារចំណាយប្រាក់ច្រើន ប៉ុន្តែពួកគេមិនទទួលបានសំណង ឬជំនួយល្អទេ។

កុមារក្រីក្រត្រូវបានគេមិនយកចិត្តទុកដាក់ ដូចជានៅក្នុងមន្ទីរពេទ្យ និងសាលារៀន ដោយសារពួកគេមិនអាចបង់ថ្លៃក្រៅផ្លូវការ និង/ឬការចំណាយបន្ថែម។

## ទីកន្លែងនៃការផ្តល់សេវាមានភាពលំបាកក្នុងការទៅទទួលសេវា

- នៅជនបទ និងជាពិសេសតំបន់ដាច់ស្រយាលមានប្រភេទសេវា និងការគាំទ្រសម្រាប់កុមារតិច និងកាន់តែតិចតួចជាងនេះសម្រាប់កុមារដែលមានពិការភាព។ កុមារជនជាតិដើមភាគតិចជាច្រើនរស់នៅតំបន់ដាច់ស្រយាល។
- ជាទូទៅ ឱកាស ឬទីកន្លែងដែលអាចទៅទទួលសេវាបានអាចនៅឆ្ងាយពេក ឬថ្លៃពេក។
- មិនមានផ្លូវជម្រាល និងឧបករណ៍សម្រាប់កុមារពិការរាងកាយ និងឬកុមារដែលមានពិការភាពផ្នែកសោតទស្សន៍ (ស្តាប់)។

កុមារនៅតំបន់ជនបទ និងដាច់ស្រយាលមិនមានអ៊ីនធឺណិតទេ ហើយនេះមានន័យថាជម្រើសមានតិចក្នុងការស្វែងរកព័ត៌មាន និងដំបូន្មាននៅពេលដែលពួកគេត្រូវការ។



ការចំណាយផ្សេងៗគឺថ្លៃសម្រាប់កុមារដែលនៅឆ្ងាយពីមណ្ឌល (ទីតាំងទទួលសេវា) ព្រោះពួកគេត្រូវចំណាយលើការធ្វើដំណើរ និងកន្លែងស្នាក់នៅ ដើម្បីចូលរួមសវនាការ (សំណុំរឿងជាមួយតុលាការ)។

សន្និដ្ឋាន៖ កុមារមានការលំបាកផ្សេងៗជាច្រើនក្នុងការទទួលបានយុត្តិធម៌ ក្រុមកុមារមួយចំនួនកាន់តែបាក់ទឹកចិត្ត (ខ្មាសអៀនកាន់តែច្រើន និងមិនសូវមានទំនុកចិត្តក្នុងការលើកឡើងពីកង្វល់)

## long and complex processes

- The court process takes a long time and is complicated because there are many steps to follow.
- There are no specific and separate avenues/options for children (like children's or family courts, ombudsperson for children).
- The process is slow, there are not enough officers and some do not react to children's concerns.
- Bribery is another problem. People pay money to delay court cases and try to win unfairly.

In one case police did not take any action for 4 years ... there might be more such cases.



In one case the accused person was invited to the process at the same time as a child.

Because things are not moving forward, children are scared and worried and their mental health suffer. Children do not see a way out and this can sometimes lead to suicides.

## children are not safe

- There is no separate room for children to ask for advice, report problems and give testimonies. Testimonies have to be repeated many times. It is very uncomfortable for children to talk about problems in front of all. It is even worse for girls in front of all male officers.
- Information from children is not kept confidential. Children are in constant fear that their information will be leaked and they will be affected by stigmatization/exclusion from school and communities they might suffer because of that.
- Some officers misuse power. Children are sometimes not treated well by police and others involved, for example bad words, yelling, threats are used.
- Children are not protected from threats during or after the process.
- This all affects children's mental health negatively.

# 2

# Process



## children are not taken seriously - respected

- Police and others belittle, ridicule or ignore children's concerns - they do not react at all or not on time on children's reports.
- Children from poor families are even less respected and cared for.

Many children experience fear toward police officers and teachers, they are afraid that their reports may be ignored or dismissed.



## children are not supported

- Generally, people think/expect children should be quiet and not speak up about problems or complain to adults. This stops children from sharing their concerns and reporting problem. This also makes it very difficult for children to participate in court procedures.
- Children usually do not get the support they need (such as explanations and advice) before, during or after any court process. Most of children do not know where to seek such support.
- Children are not told what is happening during the process, which makes them feel worried and hinders their participation.
- Children do not get psychological support during or after the process.

Some children are accompanied by a person they trust (NGO staff) before, during and after the process.

Children are not allowed by law to initiate court cases on their own, they need support - parent, lawyer.

Conclusion: The way for children to report problems, the response they get, and the court processes are not friendly and effective for children.

# ២

## ដំណើរការ



## ដំណើរការវែង និងមានភាពស្មុគស្មាញ

- ដំណើរការរបស់តុលាការត្រូវចំណាយពេលយូរ និងមានភាពស្មុគស្មាញព្រោះមានជំហានជាច្រើនត្រូវធ្វើតាម។
- មិនមានទីកន្លែង/ទីតាំងជាក់លាក់ និងដាច់ដោយឡែកសម្រាប់កុមារទេ (ដូចជាតុលាការកុមារ ឬគ្រួសារ; អ្នកតំណាងឯករាជ្យសម្រាប់កុមារ)
- ដំណើរការមានភាពយឺតយ៉ាវ មិនមានមន្ត្រីគ្រប់គ្រាន់ និងខ្វះមិនមានការឆ្លើយតបចំពោះការព្រួយបារម្ភរបស់កុមារ។
- ការស៊ីសំណូកគឺជាបញ្ហាមួយទៀត។ ប្រជាជនបង់លុយដើម្បីពន្យារសំណុំរឿងជាមួយតុលាការ ហើយព្យាយាមយកឈ្នះក្ដីដោយអយុត្តិធម៌។

មានករណីមួយប៉ូលិសមិនបានដោះស្រាយអស់រយៈពេល៤ឆ្នាំ... អាចនឹងមានករណីបែបនេះច្រើនទៀត។

ដោយសារតែអ្វីៗមិនមានដំណើរការទៅមុខ ធ្វើឱ្យកុមារមានការភ័យខ្លាច និងព្រួយបារម្ភ ហើយប៉ះពាល់ដល់សុខភាពផ្លូវចិត្តរបស់ពួកគេ។ កុមារមើលមិនឃើញមធ្យោបាយទេ ហើយនេះជួនកាលអាចឈានដល់ការធ្វើអត្តឃាត។



## កុមារមិនមានសុវត្ថិភាព

- មិនមានបន្ទប់ដាច់ដោយឡែកសម្រាប់កុមារដើម្បីសុំដំបូន្មាន រាយការណ៍បញ្ហា និងផ្ដល់ព័ត៌មាដោយផ្ទាល់ (ភត្ដុតាង)។ ភត្ដុតាងត្រូវតែធ្វើឡើងវិញជាច្រើនដង។ វាមិនពិតជាមិនមានភាពសមស្របសម្រាប់កុមារក្នុងការនិយាយអំពីបញ្ហានៅចំពោះមុខទាំងមនុស្សទាំងអស់នោះឡើយ។ វាកាន់តែអាក្រក់សម្រាប់កុមារីនៅចំពោះមុខមន្ត្រីដែលជាបុរសទាំងអស់។
- ព័ត៌មានទទួលពីកុមារមិនត្រូវបានរក្សាទុកជាសម្ងាត់។ កុមារមានការភ័យខ្លាចឥតឈប់ឈរថាព័ត៌មានរបស់ពួកគេនឹងត្រូវបានបែកធ្លាយ និងការមាក់ងាយ/ការមិនឱ្យចូលរួមក្នុងសាលារៀន និងសហគមន៍ដែលពួកគេអាចនឹងរងទុក្ខដោយសាររឿងនោះ។
- មន្ត្រីខ្លះប្រើអំណាចខុស។ ជួនកាលកុមារបានទទួលការឆ្លើយតបដោយកាយវិការមិនល្អពីប៉ូលីស និងអ្នកពាក់ព័ន្ធផ្សេងទៀត ឧទាហរណ៍ ពាក្យអាក្រក់ ការស្រែក ការគម្រាមកំហែងត្រូវបានប្រើប្រាស់។
- កុមារមិនត្រូវបានការពារពីការគំរាមកំហែងក្នុងអំឡុងពេល ឬក្រោយដំណើរការនោះទេ។
- ទាំងអស់នេះប៉ះពាល់ដល់សុខភាពផ្លូវចិត្តរបស់កុមារជាអវិជ្ជមាន។

មានករណីមួយ ជនជាប់ចោទត្រូវបានអញ្ជើញឲ្យចូលរួមក្នុងដំណើរការសាវនការក្នុងពេលដូចគ្នានឹងកុមារ។

## កុមារមិនត្រូវបានយកចិត្តទុកដាក់ខ្លាំង ឬគោរព

- ប៉ូលីស និងអ្នកដទៃមើលងាយ ចំអក ឬមិនអើពើនឹងកង្វល់របស់កុមារ - ពួកគេមិនមានការឆ្លើយតបអ្វីទាំងអស់ ឬឆ្លើយតបមិនទាន់ពេលវេលាលើរបាយការណ៍របស់កុមារ។
- កុមារមកពីគ្រួសារក្រីក្រ មិនសូវទទួលបានការគោរព និងយកចិត្តទុកដាក់។

កុមារជាច្រើនជួបប្រទះការភ័យខ្លាចចំពោះមន្ត្រីប៉ូលីស និងគ្រូបង្រៀន ពួកគេភ័យខ្លាចថារបាយការណ៍របស់ពួកគេអាចត្រូវបានទុកចោល ឬដកចេញ។



## កុមារមិនទទួលបានការគាំទ្រ

- ជាទូទៅ មនុស្សពេញវ័យគិតថា/រំពឹងថា កុមារគួរតែនៅឱ្យស្ងៀម ហើយមិនត្រូវនិយាយស្ដី ឬប្ដឹងប្ដល់ទៅលើមនុស្សពេញវ័យឡើយ។
- សកម្មភាពនេះរារាំងកុមារពីការចែករំលែកកង្វល់ និងការរាយការណ៍អំពីបញ្ហារបស់ពួកគេ។ នេះក៏បង្កការលំបាកខ្លាំងដល់កុមារក្នុងការចូលរួមក្នុងនីតិវិធីរបស់តុលាការ។
- ជាធម្មតាកុមារមិនទទួលបានការគាំទ្រដែលពួកគេត្រូវការ (ដូចជាការពន្យល់ និងដំបូន្មាន) មុន កំឡុងពេល ឬក្រោយដំណើរការតុលាការណាមួយឡើយ។ កុមារភាគច្រើនមិនដឹងថាត្រូវស្វែងរកការគាំទ្រពីកន្លែងណានោះទេ។
- កុមារមិនត្រូវបានប្រាប់ពីអ្វីដែលកំពុងកើតឡើងក្នុងអំឡុងពេលដំណើរការដែលធ្វើឱ្យពួកគេមានអារម្មណ៍ព្រួយបារម្ភ។ ដោយសារតែកុមារមិនមានព័ត៌មានគ្រប់គ្រាន់ក្នុងអំឡុងពេលដំណើរការ ពួកគេមិនអាចចូលរួមបានទេ។
- កុមារមិនទទួលបានការគាំទ្រផ្នែកចិត្តសាស្ត្រក្នុងអំឡុងពេល ឬក្រោយដំណើរការនោះទេ។

កុមារមួយចំនួនត្រូវបាន មើលថែ (ជួយ) ដោយបុគ្គលដែលពួកគេទុកចិត្ត (បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល) មុន អំឡុងពេល និងក្រោយពេលដំណើរការ។

កុមារមិនត្រូវបានអនុញ្ញាតដោយច្បាប់ដើម្បីផ្ដួចផ្ដើមសំណុំរឿងនៅតុលាការដោយខ្លួនឯងទេ ពួកគេត្រូវការការគាំទ្រ - ឪពុកម្ដាយមេធាវី។

សន្និដ្ឋានៈ មធ្យោបាយសម្រាប់កុមារក្នុងការរាយការណ៍អំពីបញ្ហា ការឆ្លើយតបដែលពួកគេទទួលបាន និងដំណើរការតុលាការមិនមានលក្ខណៈបែបកុមារមេត្រី និងប្រសិទ្ធភាពចំពោះកុមារ។

# 3

## Remedy [Solution]



### not effective

- The court process last long, decisions/remedy is often late. Bribery can make it even worse.
- Remedy is often only on paper. The solutions are just written down and not really followed.
- An apology or agreement might be made, but this does not make any change in children’s lives, and children continue to feel scared.
- People who do bad things (wrongdoers/ perpetrators/abusers) only get a short punishment, and children still feel scared.
- Children do not get any support after the process. There is nobody to check up on them or provide mental health support and help get back to school.

In one case a child had to wait 3 years for the court decision.



### not fair

- Sometimes there is pressure from powerful people to accept the decision although children and their families  disagree, but they do not have means (money and support) to complain.
- Court process is costly and at the end children do not get any compensation (remedy).
- Bribery is another problem. People pay money to delay court cases and try to win unfairly.

# ៣

## សំណង (ដំណោះស្រាយ)



### មិនសូវមានប្រសិទ្ធភាព

- ដំណើរការរបស់តុលាការមានរយៈពេលយូរ ការសម្រេចចិត្ត/សំណងតែងតែយឺតយ៉ាវ។ ការស៊ីសំណូកអាចធ្វើឱ្យវាកាន់តែអាក្រក់ទៅៗ។
- សំណងច្រើនតែមាននៅលើក្រដាស។ សំណងគឺគ្រាន់តែសរសេរហើយមិនធ្វើតាម។
- ការសុំទោស ឬការព្រមព្រៀងអាចត្រូវបានធ្វើឡើង ប៉ុន្តែនេះមិនធ្វើឱ្យមានការផ្លាស់ប្តូរណាមួយក្នុងជីវិតរបស់កុមារឡើយ ប៉ុន្តែកុមារនៅតែបន្តមានអារម្មណ៍ភ័យខ្លាច។
- មនុស្សដែលធ្វើអំពើអាក្រក់ (អ្នកធ្វើខុស/ជនល្មើស/អ្នកបំពាន) គ្រាន់តែទទួលទណ្ឌកម្មតិចតួចរយៈពេលខ្លី ហើយកុមារនៅតែមានអារម្មណ៍ភ័យខ្លាច។
- កុមារមិនទទួលបានទទួលការគាំទ្រណាមួយបន្ទាប់ពីដំណើរការ។ គ្មាននរណាម្នាក់តាមដានពិនិត្យមើលពួកគេ ឬផ្តល់ជំនួយសុខភាពផ្លូវចិត្ត និងជួយឱ្យពួកគេត្រឡប់ទៅសាលាវិញ។

មានករណីមួយកុមារត្រូវរង់ចាំ ៣ ឆ្នាំ សម្រាប់ការសម្រេចរបស់តុលាការ។



### អយុត្តិធម៌

- ពេលខ្លះមានការគាបសង្កត់ពីអ្នកដែលមានអំណាចក្នុងការឱ្យកុមារទទួលយកការសម្រេចចិត្ត ទោះបីជាកុមារ និងក្រុមគ្រួសាររបស់ពួកគេមិនយល់ស្របក៏ដោយ ប៉ុន្តែពួកគេមិនមានជម្រើស (លុយ និងការគាំទ្រ) ដើម្បីតវ៉ានោះទេ។
- ដំណើរការរបស់តុលាការត្រូវការចំណាយប្រាក់ច្រើន ហើយនៅចុងបញ្ចប់ កុមារមិនទទួលបានការសងត្រឡប់អ្វីទេ (សំណង)។
- ការស៊ីសំណូកគឺជាបញ្ហាមួយទៀត។ ប្រជាជនបង់លុយដើម្បីពន្យារសំណុំរឿងជាមួយតុលាការ ហើយព្យាយាមយកឈ្នះក្តីដោយអយុត្តិធម៌។

How can justice mechanisms be made child friendly -  more accessible, safe, effective for children?

How can children’s voices be heard in the work of justice mechanisms:

1) during proceedings
2) in design of these mechanisms?



Committee on the Rights of the Child

តើយន្តការប្រព័ន្ធយុត្តិធម៌អាចត្រូវបានបង្កើតឱ្យ
មានលក្ខណៈបែបកុមារមេត្រី ងាយក្នុងការចូល
ដំណើរការ កាន់តែមានសុវត្ថិភាព និងមាន
ប្រសិទ្ធភាពសម្រាប់កុមារ ដោយរបៀបណា?

តើសំឡេងរបស់កុមារអាចស្តាប់ឮបានដោយ
របៀបណាក្នុងការងារនៃយន្តការយុត្តិធម៌៖
១) ក្នុងអំឡុងពេលដំណើរការ
២) ក្នុងដំណាក់កាលនៃរៀប
ចំយន្តការទាំងនេះ?



គណៈកម្មការសិទ្ធិកុមារ

## child friendly justice

> Speed up adoption of the Child Protection Law.

- Create a specific law for children with a clear and child friendly mechanism so that every child can report violations of their rights.
- Create a special court (children's or family court) with specialized judge, prosecutor, lawyer, social workers.
- Create effective reporting and response mechanisms to cover all settings for a speedy and effective reaction on childrens̓ concerns.
- Make sure reporting procedures are clear/ understandable, confidential and include diverse channels so that they can be used by children in different situations and in remote areas. For example, by writing a letter and giving it through a trusted person to the local authorities.
- Train law enforcement officers at all levels in child friendly justice procedures, including how to communicate effectively with every child no matter their background.
- Provide a free lawyer to children.
- Make sure that children get psychological support before, during and after court procedures.

> Use child friendly words and keep children informed all the time during the process.

> Make sure children can report through a phone call to local authorities at all levels (village, commune, district, provincial).

> Investigate and respond to reports/ cases raised by childrens̓ clubs.

> Provide a separate room for children to report their cases.

> Provide a person of trust for children during testimony (it could be a teacher).

> Act fast on childrens̓ reports.

> Keep children safe and their information confidential during and after the process .

> Use child friendly words and methods when talking and asking questions.

> Stop abusive and discriminatory language.








## provide training for all

> Make sure that there are also female police officers, lawyers etc to make processes safer and more effective for girls.

- Train all professionals (including in health) at all levels on children's rights, reporting and justice processes so that they can give this information and advice to children.
- Train all professionals on child friendly and inclusive methods of work with all groups of children, including the most vulnerable.
- Train focal points for child protection and make sure that they are in each village.
- Increase the number of skilled officers working with children.

> Train law enforcement officers at all levels in child friendly justice procedures.

> This .training should include how to treat every child with respect and equally

> Ensure that child protection focal points have stronger connections with children's clubs.

## make remedies fair and effective

- Make sure that remedies are transparent, fair and good and effective for children.
- Make sure that remedies include psychological support, and other support children need.
- Provide budget and follow through the decisions made by courts.
- Increase collaboration between services at local level so that children can get all kind of help and support they need after the process.

> Make sure children can go to the school during and after the process.

> Stop bribery and nepotism. Stop additional fees.

## ប្រព័ន្ធយុត្តិធម៌បែបកុមារមេត្រី

ពន្លឿនការអនុម័តច្បាប់ការពារកុមារ

ប្រើពាក្យបែបកុមារ និងផ្តល់ព័តមានដល់កុមារគ្រប់ពេលវេលាក្នុងអំឡុងពេលដំណើរការ។

ត្រូវមានមនុស្សជាទីទុកចិត្តសម្រាប់កុមារអំឡុងពេលបង្ហាញភស្តុតាង (អាចជាគ្រូ)

ធានាសុវត្ថិភាពកុមារ និងរក្សាព័ត៌មានរបស់ពួកគេជាការសម្ងាត់ក្នុងអំឡុងពេល និងក្រោយដំណើរការ

- បង្កើតច្បាប់ជាក់លាក់មួយសម្រាប់កុមារដែលមានយន្តការច្បាស់លាស់ និងបែបកុមារមេត្រី ដូច្នេះកុមារគ្រប់រូបអាចរាយការណ៍ពីការរំលោភសិទ្ធិរបស់ពួកគេបាន។
- បង្កើតតុលាការពិសេស (តុលាការកុមារ ឬគ្រួសារ) ដែលមានចៅក្រមឯកទេស ព្រះរាជអាជ្ញា មេធាវី បុគ្គលិកសង្គមកិច្ច។
- បង្កើតយន្តការរាយការណ៍ និងការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ដើម្បីគ្របដណ្តប់គ្រប់តំបន់សម្រាប់ពន្លឿន និងប្រសិទ្ធភាពចំពោះការឆ្លើយតបលើកង្វល់របស់កុមារ។
- ត្រូវប្រាកដថានីតិវិធីរាយការណ៍មានភាពច្បាស់លាស់/អាចយល់បាន សម្ងាត់ និងបរិយាបន្ន ដូច្នេះកុមារអាចប្រើប្រាស់បានក្នុងស្ថានភាពផ្សេងៗគ្នា និងនៅតំបន់ដាច់ស្រយាល។ ជាឧទាហរណ៍ តាមរយៈការសរសេរសំបុត្រមួយច្បាប់ ហើយប្រគល់វាតាមរយៈបុគ្គលដែលទុកចិត្ត និងប្រគល់ដល់អាជ្ញាធរមូលដ្ឋាន។
- បណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់គ្រប់លំដាប់ថ្នាក់ក្នុងនីតិវិធីយុត្តិធម៌បែបកុមារមេត្រី រួមទាំងរបៀបដាក់បណ្តឹង (ប្រាស្រ័យទាក់ទង) ប្រកបដោយប្រសិទ្ធភាពជាមួយកុមារគ្រប់រូប មិនថាពួកគេមានប្រវត្តិយ៉ាងណា ឬមកពីណា។
- ផ្តល់សេវាមេធាវីដោយឥតគិតថ្លៃដល់កុមារ។
- ត្រូវប្រាកដថាកុមារទទួលបានការគាំទ្រផ្នែកចិត្តសាស្ត្រមុន អំឡុងពេល និងក្រោយនីតិវិធីរបស់តុលាការ

ត្រូវប្រាកដថាកុមារអាចរាយការណ៍តាមរយៈការហៅទូរស័ព្ទទៅកាន់អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ (ភូមិ ឃុំ ស្រុក ខេត្ត)។

ស៊ើបអង្កេត និងឆ្លើយតបទៅនឹងរបាយការណ៍/ករណីដែលលើកឡើងដោយក្លឹបកុមារ។

ផ្តល់បន្ទប់ដាច់ដោយឡែកមួយសម្រាប់កុមារដើម្បីរាយការណ៍ករណីរបស់ពួកគេ។

ប្រើប្រាស់ពាក្យ និងវិធីសាស្ត្រដែលងាយយល់ដល់កុមារនៅពេលនិយាយ និងសួរសំណួរ។ (១៩ វិច្ឆិកា)

បញ្ឈប់ការប្រើប្រាស់ភាសាដែលនាំឱ្យមានការរំលោភបំពាន និងរើសអើង



១ — **ការចូលប្រើប្រាស់**



២ — **ដំណើរការ**



៣ — **សំណង**





## ផ្តល់ការបណ្តុះបណ្តាលសម្រាប់ទាំងអស់គ្នា

ត្រូវប្រាកដថាមានមន្ត្រីប៉ូលីសស្រី មេធាវីស្រីជាដើម ដើម្បីធ្វើឱ្យដំណើរការមានសុវត្ថិភាព និងមានប្រសិទ្ធភាពជាងមុនសម្រាប់កុមារី

- បណ្តុះបណ្តាលអ្នកជំនាញទាំងអស់ (រួមទាំងផ្នែកសុខភាព) នៅគ្រប់កម្រិតទាំងអស់អំពីសិទ្ធិកុមារ ការរាយការណ៍ និងដំណើរការយុត្តិធម៌ ដូច្នេះពួកគេអាចផ្តល់ព័ត៌មាន និងដំបូន្មានទាំងនេះដល់កុមារ។
- បណ្តុះបណ្តាលអ្នកជំនាញទាំងអស់អំពីវិធីសាស្ត្របែបកុមារមេត្រី និងបរិយាបន្នជាមួយក្រុមកុមារទាំងអស់ រួមទាំងកុមារដែលងាយរងគ្រោះបំផុត។
- បណ្តុះបណ្តាលជនបង្គោលអំពីកិច្ចការការពារកុមារ និងធ្វើឱ្យប្រាកដថាជនបង្គោលមាននៅគ្រប់ភូមិ។
- បង្កើនចំនួនមន្ត្រីជំនាញដែលធ្វើការជាមួយកុមារ។

ត្រូវប្រាកដថាជនបង្គោលការពារកុមារមានទំនាក់ទំនងកាន់តែរឹងមាំជាមួយក្លឹបកុមារ។

បណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់គ្រប់លំដាប់ថ្នាក់ពីនីតិវិធីយុត្តិធម៌បែបកុមារមេត្រី។

វគ្គបណ្តុះបណ្តាលនេះគួរតែរួមបញ្ចូលពីរបៀបនៃការឆ្លើយតបចំពោះកុមារគ្រប់រូបដោយការគោរព និងស្មើភាពគ្នា។

## ធ្វើឱ្យសំណងមានភាពត្រឹមត្រូវ និងមានប្រសិទ្ធភាព

- ត្រូវប្រាកដសំណងមានតម្លាភាព យុត្តិធម៌ និងសមស្រប និងមានប្រសិទ្ធភាពសម្រាប់កុមារ។
- ត្រូវប្រាកដថា សំណងរួមទាំងជំនួយផ្លូវចិត្ត និងជំនួយផ្សេងទៀតដែលកុមារត្រូវការបានផ្តល់ជូនពួកគេ។
- ផ្តល់ថវិកា និងអនុវត្តតាមសេចក្តីសម្រេចដែលធ្វើឡើងដោយតុលាការ។
- បង្កើនកិច្ចសហការរវាងសេវាកម្មនៅថ្នាក់មូលដ្ឋាន ដើម្បីឱ្យកុមារអាចទទួលបានជំនួយ និងការគាំទ្រគ្រប់ប្រភេទដែលពួកគេត្រូវការបន្ទាប់ពីដំណើរការ

បញ្ឈប់ការស៊ីសំណូក និងបក្សពួកនិយម។ បញ្ឈប់ការយកថ្លៃបន្ថែម។

ត្រូវប្រាកដថាកុមារអាចទៅសាលារៀនបានក្នុងអំឡុងពេល និងក្រោយពេលដំណើរការ

What do children need to access justice and effective remedy if their rights got violated?

What do children need to participate in this process?



Committee on the Rights of the Child

តើកុមារត្រូវការអ្វីខ្លះដើម្បីទទួលបានយុត្តិធម៌ និងសំណាងដ៏មានប្រសិទ្ធភាព ប្រសិនបើសិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពាន?

តើកុមារត្រូវការអ្វីខ្លះដើម្បីចូលរួមក្នុងដំណើរការនេះ?



គណៈកម្មការសិទ្ធិកុមារ

Peer education is important. Support peer education programs around the country. Make sure children with different backgrounds can join.

## raise childrenś awareness

- Raise children awareness on children's rights, reporting and justice procedures.
- This information should be easy to understand, complete and available everywhere, including online and in different languages and formats.
- All professionals, in schools, in hospitals, police and so on, should inform all children about what can be done when their rights are violated.
- NGOs should provide this information too on a more regular basis as part of general information on childrenś rights.
- Child rights education in schools or by NGOs should include information about what to do when childrenś rights are violated.

Continue raising awareness about the child protection focal points in the communes, including where and how children can seek support and report cases.








## provide support for parents

- Raise awareness and skills of parents to be able to support children in reporting and justice processes.
- Provide support to parents to increase their communication skills and enable them to listen and talk to their children.
- Support parents to be able to solve problems without violence.
- Raise awareness of parents that resorting to bribery and out-of court settlements is harmful to children

Prioritize children's best interests by involving them actively in decisions in different settings - family, school, community and so on.

## consult with children regularly

- Continue consultations with children about the issues they face when accessing justice and remedies and act on their suggestions
- Invite children to the meetings of authorities at local level (commune, province) regularly and ask for feedback about how services work and what can be improved including in respect of reporting and responding to cases.
- Regular meetings with children, for example once a month will help build better relationships, learn from each other and make better decisions that respect the best interests of children.
- Provide regular updates to children regarding the progress and responses to their suggestions, ensuring they are informed about the outcomes.

Make sure that children are safe and supported before, during and after the consultations. Address their needs promptly.

Integrate childrenś needs and inputs into the Commune Investment/Budgetary Plan through meaningful childrenś participation.

Increase opportunities for children to voice their concerns.

Provide clear and timely updates on the progress of their cases or reports.



> មិត្តអប់រំមិត្តគឺសំខាន់។ គាំទ្រកម្មវិធីមិត្តអប់រំមិត្តទូទាំងប្រទេស។ ត្រូវប្រាកដថាកុមារដែលមានប្រវត្តិ និងក្រុមផ្សេងៗគ្នាអាចចូលរួមបាន។

## លើកកម្ពស់ការយល់ដឹងរបស់កុមារ

> បន្តលើកកម្ពស់ការយល់ដឹងដល់ជនបង្គោលការពារកុមារនៅក្នុងឃុំ រួមទាំងទីកន្លែង និងរបៀបដែលកុមារអាចស្វែងរកការគាំទ្រ និងរាយការណ៍ករណី។

- លើកកម្ពស់ការយល់ដឹងរបស់កុមារអំពីសិទ្ធិកុមារ ការរាយការណ៍ និងនីតិវិធីយុត្តិធម៌។
- ព័ត៌មានគួរតែមានភាពងាយស្រួលក្នុងការយល់ពេញលេញ និងមាននៅគ្រប់ទីកន្លែង រួមទាំងអនឡាញ និងមានចម្រុះភាសាផ្សេងៗគ្នា។
- អ្នកជំនាញ ទាំងនៅសាលារៀន មន្ទីរពេទ្យ ប៉ូលីស និងផ្សេងៗទៀត គួរតែជូនដំណឹងដល់កុមារទាំងអស់អំពីអ្វីដែលអាចធ្វើបាននៅពេលដែលសិទ្ធិរបស់កុមារត្រូវបានរំលោភបំពាន។
- អង្គការក្រៅរដ្ឋាភិបាលគួរតែផ្តល់ព័ត៌មាននេះផងដែរដែលជាផ្នែកនៃព័ត៌មានទូទៅអំពីសិទ្ធិកុមារ។
- ការអប់រំសិទ្ធិកុមារនៅក្នុងសាលារៀន ឬដោយអង្គការក្រៅរដ្ឋាភិបាលគួរតែរួមបញ្ចូលព័ត៌មានអំពីអ្វីដែលត្រូវធ្វើនៅពេលដែលសិទ្ធិកុមារត្រូវបានរំលោភបំពាន។






### ការចូលប្រើប្រាស់



### ដំណើរការ



### សំណាង





## ការគាំទ្រដល់ឪពុកម្តាយ

- លើកកម្ពស់ការយល់ដឹង និងជំនាញរបស់មាតាបិតា ដើម្បីអាចគាំទ្រដល់កុមារក្នុងការរាយការណ៍ និងដំណើរការយុត្តិធម៌។
- ផ្តល់ការគាំទ្រដល់ឪពុកម្តាយដើម្បីបង្កើនជំនាញទំនាក់ទំនងរបស់ពួកគេ និងធ្វើឱ្យពួកគេស្តាប់ និងនិយាយជាមួយកូនរបស់ពួកគេ។
- គាំទ្រឪពុកម្តាយឱ្យចេះដោះស្រាយបញ្ហាដោយគ្មានអំពើហឹង្សា (ប្រើប្រាស់គំរូអហិង្សា)។
- លើកកម្ពស់ការយល់ដឹងរបស់មាតាបិតាថាការទទួលសំណូក និងការដោះស្រាយក្រៅតុលាការគឺមានគ្រោះថ្នាក់ និងបង្កការឈឺចាប់ដល់កុមារ។

> ផ្តល់អាទិភាពដល់ឧត្តមប្រយោជន៍របស់កុមារ ដោយការចូលរួមពួកគេយ៉ាងសកម្មក្នុងការសម្រេចចិត្តនៅក្នុងការកំណត់ផ្សេងៗគ្នា ដូចជា គ្រួសារ សាលារៀន សហគមន៍ជាដើម។

## មតិត្រឡប់ពីកុមារ

> បង្កើនឱកាសឱ្យកុមារបញ្ចេញនូវកង្វល់របស់ពួកគេ។

- បន្តការពិគ្រោះយោបល់ជាមួយកុមារអំពីបញ្ហាដែលពួកគេប្រឈមនៅពេលគេទៅទទួលសេវាយុត្តិធម៌ និងសំណងហើយធ្វើការឆ្លើយតបតាមការស្នើសុំរបស់ពួកគេ។
- អញ្ជើញកុមារឱ្យចូលរួមកិច្ចប្រជុំរបស់អាជ្ញាធរនៅថ្នាក់មូលដ្ឋាន (ឃុំ-សង្កាត់) ឱ្យបានទៀងទាត់ ហើយសុំមតិកែលម្អអំពីរបៀបដែលសេវាដំណើរការ និងអ្វីដែលអាចកែលម្អ រួមទាំងការគោរពការរាយការណ៍ និងឆ្លើយតបករណី។
- ប្រជុំជាទៀងទាត់ជាមួយកុមារ ជាឧទាហរណ៍មួយខែម្តងនឹងជួយបង្កើតទំនាក់ទំនងកាន់តែប្រសើរឡើង រៀនពីគ្នាទៅវិញទៅមក និងធ្វើការសម្រេចចិត្តបានល្អប្រសើរ ដែលគោរពឧត្តមប្រយោជន៍របស់កុមារ។
- ផ្តល់ព័ត៌មានថ្មីៗជាប្រចាំដល់កុមារទាក់ទងនឹងវឌ្ឍនភាព និងការឆ្លើយតបចំពោះសំណើរបស់ពួកគេ ដោយធានាថាពួកគេត្រូវបានគេជូនដំណឹងអំពីលទ្ធផល។

> ត្រូវប្រាកដថាកុមារមានសុវត្ថិភាព និងគាំទ្រ ទាំងមុន ក្នុងកំឡុងពេល និងក្រោយការពិគ្រោះយោបល់។ ដោះស្រាយតម្រូវការរបស់ពួកគេភ្លាមៗ។

> បញ្ចូលតម្រូវការ និងធាតុចូលរបស់កុមារទៅក្នុងផែនការវិនិយោគ/ថវិកាឃុំ តាមរយៈការចូលរួមរបស់កុមារប្រកបដោយភាពពេញលេញ។

> ផ្តល់ព័ត៌មានថ្មីៗច្បាស់លាស់ និងទាន់ពេលវេលាលើដំណើរការនៃករណី ឬរបាយការណ៍របស់ពួកគេ។



# next steps

- CRC-Cambodia will
  - submit this report to the Committee
  - follow developments related to the General Comment 27
  - keep children informed through NGO-members
  - try to raise funds to organize consultations with children on the first draft of the General Comment



**2025**

- First draft of the General Comment 27
- Second round of consultations.

**2026**

- General Comment 27 finalized and published.



# ជំហានបន្ទាប់

- អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា នឹង
    - បញ្ជូនរបាយការណ៍នេះទៅគណៈកម្មាធិការ។
    - តាមដានការវិវឌ្ឍន៍ដែលទាក់ទងនឹងមតិទូទៅ ២៧។
    - ផ្តល់ព័ត៌មានដល់កុមារតាមរយៈសមាជិកអង្គការក្រៅរដ្ឋាភិបាល។
    - ព្យាយាមរកថវិកាដើម្បីរៀបចំការពិគ្រោះយោបល់ជាមួយកុមារលើសេចក្តីព្រាងដំបូងនៃសេចក្តីមតិទូទៅ។



២០២៥

- សេចក្តីព្រាងដំបូងនៃមតិទូទៅ ២៧។
- ជុំទីពីរនៃការពិគ្រោះយោបល់។

២០២៦

- មតិទូទៅ ២៧ បានបញ្ចប់ និងបោះពុម្ពផ្សាយ។

